*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦*

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Technical Working Group "PFMTWG") ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ សមាជិក និងមន្ត្រី ពីគ្រប់ក្រសួង/ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ ។

កិច្ចប្រជុំក្រុមការងារបច្ចេកទេស "PFMTWG" គឺជាយន្តការសម្របសម្រួលមួយក្នុងចំណោមយន្តការសម្របសម្រួលថ្នាក់ជាតិទាំង ១៩ របស់រាជរដ្ឋាភិបាលដែលបានបង្កើតឡើងសម្រាប់តាមដាន និងពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍នានាលើការងារត្រួតពិនិត្យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅធ្វើការផ្សព្វផ្សាយជាផ្លូវការ និងជាសាធារណៈនូវរបាយការណ៍សកម្មភាពកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់គ្រប់ក្រសួង-ស្ថាប័នដែលបានអនុវត្តន៍កន្លងមក ។

ដោយមានការឯកភាពពីគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កិច្ចប្រជុំនេះគឺដើម្បីត្រួតពិនិត្យវឌ្ឍនភាពប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបាន និងកំពុងអនុវត្តដោយគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ដើម្បីពិភាក្សា និងអនុម័តលើប្រធានបទសំខាន់ៗសម្រាប់ជាកម្មវត្ថុនៃកិច្ចការរៀបចំកម្មវិធីប្រកាសដាក់ឱ្យអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី ៣ (Consolidated Action Plan 3 "CAP 3") សម្រាប់ ៥ ឆ្នាំ ខាងមុខ ។ ប្រធានបទ ៤ ត្រូវបានលើកយកមកពិភាក្សា៖

**(១) ត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០១៥៖**

ជាលទ្ធផល អង្គប្រជុំបានឯកភាពលើរបាយការណ៍វឌ្ឍនភាពដែលបានបង្ហាញជូន និងបានផ្តល់អនុសាសន៍កែលម្អថ្មីៗបន្ថែមទៀតផងដែរ ។

**(២) ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដោយប្រើក្របខ័ណ្ឌវាស់សមិទ្ធកម្មរបស់ PEFA៖**

ការវាយតម្លៃនេះ ត្រូវបានបញ្ចប់ជាស្ថាពរ ដោយក្រុមការងារអគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សហការជាមួយលេខាធិការដ្ឋាន Public Expenditure and

Financial Accountability “PEFA” នៅទីក្រុងវ៉ាស៊ីនតោន និងកំពុងរង់ចាំការផ្តល់សុពលភាពចុងក្រោយពីលេខាធិការដ្ឋាននេះ ។

(៣) **ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ “CAP 3” សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷**

អង្គប្រជុំទទួលបាននូវព័ត៌មានបច្ចុប្បន្នភាពស្តីពីវឌ្ឍនភាពនៃការរៀបចំ “CAP 3” សម្រាប់ការឈានទៅអនុវត្តដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពោលគឺការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនៅឆ្នាំ ២០១៦ ដោយទទួលបានអនុសាសសន៍ថ្មីៗពីដៃគូអភិវឌ្ឍន៍ជាពិសេស អនុសាសន៍ទទួលបានពីការវាយតម្លៃ PEFA ។ ជាលទ្ធផលអង្គប្រជុំបានឯកភាពទាំងស្រុងលើក្របខ័ណ្ឌនេះ និងសម្រេចយក “CAP 3” ដើម្បីត្រៀមដាក់ក្នុងពិធីប្រកាសជាផ្លូវការនៅពេលខាងមុខ ។

(៤) **របៀបវារៈពិធីប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី ៣ និងកិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពប្រចាំឆ្នាំ ២០១៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷**

អង្គប្រជុំបានពិនិត្យ កែលម្អលើរបៀបវារៈទាំងពីរនេះ ដែលត្រូវបានស្នើឡើងដោយ**អគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។**

តំណាងដៃគូអភិវឌ្ឍន៍បានវាយតម្លៃថាកម្មវិធីមានវឌ្ឍនភាពគួរជាទីមោទនៈ និងបានថ្លែងសាទរដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នាពេលនេះក៏ដូចជាការត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆ្នាំនាពេលខាងមុខ និងបានផ្តល់នូវអនុសាសន៍កែលម្អមួយចំនួនលើកិច្ចការងារកែទម្រង់កន្លងមក ក្នុងនោះរួមមាន ការងារត្រៀមរៀបចំដាក់ឲ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ក៏ដូចជាកិច្ចដំណើរការនៃការកែទម្រង់ប្រព័ន្ធថវិកាផងដែរ ។ តំណាងដៃគូអភិវឌ្ឍន៍ ក៏បានគូសបញ្ជាក់ពីការបន្តគាំទ្ររាជរដ្ឋាភិបាលលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅជំហានបន្តបន្ទាប់ ។

កិច្ចប្រជុំក្រុមការងារបច្ចេកទេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏បានប្រមូលនូវធាតុចូលសំខាន់ៗបន្ថែម និងអនុម័តរួមគ្នាលើគោលការណ៍ និងខ្លឹមសារឯកសារសម្រាប់អនុវត្តបន្ត ហើយឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ក៏បានផ្តល់អនុសាសន៍ និងណែនាំជាវិធានការណ៍សម្រាប់អនុវត្តបន្តផងដែរ ៕